MASSACHUSETTS DEPARTMENT OF
UNEMPLOYMENT ASSISTANCE

# សម្រាប់និយោជិតនៅរដ្ឋម៉ាស្សាជូសិត៖ របៀបដាក់ពាក្យទាមទារតាវកាលិកក្នុងកម្មវិធីធានារ៉ាប់រងនិកម្មភាព

## សម្រាប់និយោជកនៅរដ្ឋម៉ាស្សាជូសិត៖

**យោងតាមច្បាប់ការងារ និងបណ្ដុះបណ្ដាលរដ្ឋ M.G.L ជំពូក 151A អ្នកត្រូវតែផ្ដល់ចែកចាយខិត្តិប័ណ្ណផ្សព្វផ្សាយនេះឲ្យបាន ឆាប់តាមលទ្ធភាពដែលអាចធ្វើបាន ប៉ុន្តែមិនឲ្យហួសរយៈពេល 30 ថ្ងៃទេ គិតចាប់ពីចុងក្រោយ ដែលនិយោជិតបំពេញការងារមានប្រាក់ឈ្នួល។ អ្នកត្រូវតែចែកចាយខិត្តប័ណ្ណផ្សព្វផ្សាយនេះដល់និយោជិតម្នាក់ៗរបស់អ្នក ដែលត្រូវបានកាត់ចេញពីការងារបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍។ សូមបំពេញព័ត៌មាននៅផ្នែកខាងក្រោម៖**

---

**ឈ្មោះនិយោជក**

---

**អាសយដ្ឋានប្រៃសនីយ៍**

---

**លេខទូរស័ព្ទ**

---

**លេខសម្គាល់និយោជកសហព័ន្ធ**



# ដាក់ពាក្យ តាម ប្រព័ន្ធ អ៊ីនធឺណិត

ដើម្បីដាក់ពាក្យទាមទារតាវកាលិកពីកម្មវិធី UI ថ្មី ឬបើកឯកសារដាក់ពាក្យទាមទារដែលបង្កើតរួចជាថ្មី សូមចូលទៅកាន់គេហទំព័ររបស់យើងខ្ញុំ៖ mass.gov/unemployment-insurance-ui-for-workers។

ដើម្បីដាក់ពាក្យទាមទារអនឡាញ អ្នកត្រូវតែបង្កើតគណនីផ្ទាល់ខ្លួនដោយចូលទៅ mass.gov/how-to/register-for-a-mymassgov-personal-account។

1. ចូលទៅសេវាកម្មតាវកាលិកនិកម្មភាពនៅ mass.gov/dua ហើយឡុកចូលដោយប្រើគណនី **MyMassGov** លោកអ្នក។
2. សូមអាន *កិច្ចយល់ព្រមអ្នកដាក់ពាក្យទាមទារ* ដោយធិកក្នុងប្រអប់ថាអ្នកបានអានវា ហើយជ្រើសយក **’Next”**។
3. នៅពេលអ្នកត្រូវបានប្រាប់ អ្នកនឹងត្រូវបានសួររកលេខសង្គមសន្តិសុខ និងកាលបរិច្ឆេទកំណើត។ ជ្រើសយក **“Next”**។
4. បន្តជាមួយនឹងការដាក់សុំដោយធ្វើតាមពាក្យណែនាំ។
5. នៅពេលធ្វើចប់ហើយ អ្នកនឹងត្រូវបានបញ្ជូនត្រឡប់ទៅអាក្រង់ដើមវិញ។

## ត្រូវការជំនួយ?

ប្រសិនបើអ្នកមានសំណួរទាក់ទងនឹងសិទ្ធិអ្នក សូមពិនិត្យមើលលក្ខខណ្ឌសិទ្ធិតាមគេហទំព័រ៖ mass.gov/dua/eligibility.

សម្រាប់ជំនួយអំពីការបង្កើតគណនី **online** សូមចូលមើលគេហទំព័រ៖ mass.gov/dua.

# ព័ត៌មានតម្រូវមាន សម្រាប់ដាក់ពាក្យទាមទារ តាវកាលិក

ក្នុងការដាក់ពាក្យទាមទារតាវកាលិកនិកម្មភាព អ្នកត្រូវផ្តល់ព័ត៌មានផ្ទាល់ខ្លួន រួមមានលេខសម្គាល់របបសន្តិសុខសង្គម ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋានរស់នៅ អ៊ីម៉ែល និងលេខទូរស័ព្ទរបស់អ្នកជាដើម។

អ្នកក៏ត្រូវការព័ត៌មាន អំពីប្រវត្តិការងាររបស់អ្នករយៈពេល 15 ខែចុងក្រោយ រួមមាន៖

- ឈ្មោះនិយោជកទាំងអស់ រួមទាំងអាសយដ្ឋាន និងលេខទូរស័ព្ទ
- មូលហេតុនៃការឈប់ពីការងារទាំងនោះ
- កាលបរិច្ឆេទចូលធ្វើការ និងឈប់ធ្វើការ
- កាលបរិច្ឆេទចូលធ្វើការវិញ (បើអ្នកត្រូវបានរំសាយ ប៉ុន្តែកំណត់កាលបរិច្ឆេទចូលធ្វើការវិញ)

អ្នកអាចត្រូវការព័ត៌មានបន្ថែម ប្រសិនបើ៖

- អ្នកមិនមែនជាពលរដ្ឋអាមេរិក — លេខចុះបញ្ជីសញ្ជាតិលេខ ផ្ទៀងផ្ទាត់របស់អ្នកអនុញ្ញាតឲ្យអ្នកធ្វើការនៅសហរដ្ឋអាមេរិក
- អ្នកមានកូនក្នុងបន្ទុក — ថ្ងៃខែឆ្នាំកំណើត និងលេខសម្គាល់របបសន្តិសុខសង្គមរបស់ពួកគេ
- អ្នកជាសមាជិកសហជីព — ឈ្មោះសហជីព និងលេខទំនាក់ទំនង
- អ្នកជាយោធា — ទម្រង់សមាជិក *DD-214 របស់អ្នក*។ ប្រសិនបើអ្នកមិនមានទម្រង់នេះទេ អ្នកអាចស្នើសុំទម្រង់ *DD-214* របស់អ្នកបានតាមគេហទំព័រ dd214.us.



# ដាក់ពាក្យតាមទូរស័ព្ទ

ដើម្បីដាក់ពាក្យទាមទារតាវកាលិកថ្មីពីកម្មវិធី UI ឬបើកឯកសារដាក់ពាក្យទាមទារដែលបង្កើតរួចជាថ្មី តាមទូរស័ព្ទទៅមជ្ឈមណ្ឌល TeleClaim លេខ (877) 626-6800។

**មជ្ឈមណ្ឌល TeleClaim បើក ពីម៉ោង 8:30 ព្រឹក ដល់ម៉ោង 4:30 ល្ងាច ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។**

## ដើម្បីទទួលបានប្រាក់ទូទាត់ដោយផ្ទាល់

អ្នកនឹងត្រូវការឈ្មោះធនាគារ និងលេខបើកប្រាក់របស់អ្នកិ។ ឬក្រសួង DUA នឹងផ្ញើប័ណ្ណឥណពន្ធទៅអ្នក។

# អ្វីទៅជាសេវាធានារ៉ាប់រងនិកម្មភាព?

សេវាធានារ៉ាប់រងនិកម្មភាព (UI) គឺជាកម្មវិធីផ្តល់ជំនួយជាប្រាក់ចំណូលបណ្តោះអាសន្ន សម្រាប់
និយោជិតនៅរដ្ឋម៉ាស្សាជូសេត ដែលបានបាត់បង់ការងារដោយមិនមានកំហុស
និង៖

- អាចធ្វើការបាន
- មានពេលវេលាសម្រាប់ធ្វើការ និង
- កំពុងស្វែងរកការងារធ្វើយ៉ាងសកម្ម

មូលនិធិសម្រាប់តាវកាលិកក្នុងកម្មវិធី UI បានមកពីវិភាគទានប្រចាំត្រីមាស ដែលនិយោជកនៅក្នុងរដ្ឋនេះ បង់ឲ្យក្រសួងជំនួយនិកម្មភាព។ និយោជិតមិនបង់វិភាគទានដល់សេវាកម្មធានារ៉ាប់រងនិកម្មភាព។

# តើអ្នកគួរដាក់ពាក្យស្នើសុំតាវកាលិកពីកម្មវិធី UI នៅពេលណា?

ប្រសិនបើអ្នកត្រូវបានកាត់ចេញពីការងារ ឬក៏ម៉ោងធ្វើការរបស់អ្នកត្រូវបានកាត់បន្ថយ អ្នកគួរតែដាក់ពាក្យទាមទារតាវកាលិកពីកម្មវិធី UI អំឡុងសប្តាហ៍ទីមួយ ដែលអ្នកអត់មានការងារធ្វើទាំងស្រុង ឬដោយផ្នែក។ ដំណើរការទាមទាររបស់អ្នក នឹងចាប់ផ្តើម
នៅថ្ងៃអាទិត្យនៃសប្តាហ៍ប្រតិទិន ដែលអ្នក
បានដាក់ពាក្យទាមទារ។ កាលបរិច្ឆេទហៅថាកាលបរិច្ឆេទទាមទារផ្លូវការ។

អ្នកនឹងមិនទទួលតាវកាលិកទេ សម្រាប់សប្តាហ៍ដែលអ្នកអត់មានការងារមុនកាលបរិច្ឆេទទាមទារផ្លូវការទេ។

**កំណត់សម្គាល់សំខាន់៖**
អ្នកអាចស្នើសុំតាវលិកបាន តែនៅពេលដែលអ្នក
នៅក្នុងសហរដ្ឋអាមេរិក
ទឹកដីគ្រប់គ្រងដោយសហរដ្ឋអាមេរិក ឬក៏ប្រទេសកាណាដាប៉ុណ្ណោះ។ អ្នកមិនគួរស្នើសុំតាវកាលិក
សម្រាប់សប្តាហ៍ដែលអ្នកនៅក្រៅសហរដ្ឋ
អាមេរិកទឹកដីគ្រប់គ្រងដោយសហរដ្ឋអាមេរិក ឬក៏ប្រទេសកាណាដាទេ។

This pamphlet includes important information on how to apply for Unemployment Insurance benefits.

Este folleto contiene información importante sobre cómo solicitar los beneficios del Seguro de Desempleo.

Este panfleto contém informações importantes sobre como registrar-se para receber benefícios de subsídio de desemprego.

Данный проспект содержит важную информацию о процессе подачи заявления на получение Страхового пособия по безработице.

Livrè sa gen enfòmasyon enpòtan sou fason pou aplike pou Benefis Asirans Chomaj yo.

Il presente opuscolo contiene importanti informazioni riguardanti la modalità di richiesta per l'indennità di disoccupazione.

Cette brochure comporte d'importants renseignements sur la façon de demander des prestations d'assurance-chômage.

សៀវភៅផ្សព្វផ្សាយនេះមានរួមជាមួយនឹងព័ត៌មានសំខាន់ អំពី
របៀបដាក់ពាក្យសុំប្រាក់អត្ថប្រយោជន៍ការធានារ៉ាប់រងការគ្មាន
ការងារ។

**Cuốn sách mỏng này bao gồm thông tin quan trọng về cách nộp đơn xin bảo hiểm thất nghiệp**

ແຜ່ນເຈ້ຍນີ້ມີຂໍ້ມູນກ່ຽວກັບວິທີການຂໍເອົາເງິນຜົນປະໂຫຍດປະກັນໄພ
ຫວ່າງງານ.

这本小册子包括如何申请失业保险金的重要信息.

이 팜플렛에는 실업 보험 급여의 신청 방법에 대한 중요한 정보가 들어 있습니다.

يحتوي هذا الكتيب على معلومات هامة حول كيفية التقديم للحصول على منافع تأمين البطالة.

## កម្មវិធីឱកាសស្មើភាពសម្រាប់និយោជក

**ជំនួយ និងសេវាកម្មពិសេសមាន សម្រាប់ឆ្លើយតបតាមសំណើ ដល់ជនពិការ។ សម្រាប់សេវាអ្នកមានបញ្ហាផ្ទៃកស្តាប់ សូម ទូរស័ព្ទទៅលេខ 711។**

MASSACHUSETTS DEPARTMENT OF
**UNEMPLOYMENT ASSISTANCE**